ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មាន
## របស់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.ច.ក-១៩)
## ស្តីពី
## យុទ្ធនាការចាក់វ៉ាក់សាំងកូវីសែល (COVISHIELD) ដែលទទួលបានអាជ្ញាបណ្ណផលិតពី អាស្ត្រាហ្សេនីកា (AstraZeneca) សម្រាប់ក្រុមមនុស្សអាយុពី៦០ឆ្នាំឡើងនៅរាជធានីភ្នំពេញ

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) សូមជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា ដោយសារតែស្ថានភាពជាក់ស្តែងនៃការរីករាលដាលជំងឺកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជាមិនទាន់មានការថមថយនៅឡើយនោះ និងយោងតាមរបាយការណ៍អង្គការសុខភាពពិភពលោកបានរកឃើញថា ក្រុមមនុស្សវ័យចាស់គឺជាក្រុមងាយរងគ្រោះខ្ពស់បើមានការចម្លងជំងឺកូវីដ-១៩ វាងាយវិវត្តន៍ទៅជាធ្ងន់ធ្ងរ និងបណ្តាលឱ្យមានអត្រាស្លាប់ខ្ពស់ ការប្រើប្រាស់វ៉ាក់សាំងកូវីដ-១៩ គឺជាឧបករណ៍ដ៏សំខាន់មួយ នៅក្នុងការរួមចំណែកបង្ការភាពធ្ងន់ធ្ងរពីការរីករាលដាលនៃជំងឺដ៏កាចសាហាវនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់អាទិភាពដល់ក្រុមមនុស្សដែលមានអាយុវ័យចាស់ឱ្យទទួលបានវ៉ាក់សាំងកូវីដ-១៩ ឱ្យបានឆាប់បំផុតដែលអាចធ្វើបាន។

ដោយមានការសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស សូមជម្រាបជូនដល់សាធារណជនទាំងអស់ថា យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងកម្រិតចំនួន៥៥.៧០០នាក់ ដែលមានអាយុចាប់ពី៦០ឆ្នាំឡើងនៅរាជធានីភ្នំពេញ និងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ តទៅចាប់ពីម៉ោង ០៨:០០នាទីព្រឹក នៅតាមទីតាំងដូចខាងក្រោម ៖

| ល.រ | ឈ្មោះរដ្ឋបាលខណ្ឌ | ឈ្មោះមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក |
|---|---|---|
| ១ | ខណ្ឌចំការមន | មណ្ឌលសុខភាពផ្សារដើមថ្កូវ |
| ២ | ខណ្ឌបឹងកេងកង | មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ |
| ៣ | ខណ្ឌ៧មករា | មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ |
| ៤ | ខណ្ឌទួលគោក | មណ្ឌលសុខភាពទួលគោក |
| ៥ | ខណ្ឌដូនពេញ | មន្ទីរពេទ្យបង្អែកចតុមុខ |
| ៦ | ខណ្ឌជ្រោយចង្វារ | មណ្ឌលសុខភាពជ្រោយចង្វារ |
| ៧ | ខណ្ឌឬស្សីកែវ | មណ្ឌលសុខភាពគីឡូម៉ែត្រលេខ៦ |
| | | មន្ទីរពេទ្យបង្អែកសម្តេចឪ-សម្តេចម៉ែ |
| ៨ | ខណ្ឌពោធិ៍សែនជ័យ | មណ្ឌលសុខភាពសាមគ្គី |
| | | មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង |
| ៩ | ខណ្ឌកំបូល | មណ្ឌលសុខភាពបឹងធំ |
| ១០ | ខណ្ឌច្បារអំពៅ | មណ្ឌលសុខភាពព្រែកឯង |
| | | មន្ទីរពេទ្យបង្អែកច្បារអំពៅ |



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

| | | |
|---|---|---|
| ១១ | ខណ្ឌមានជ័យ | មណ្ឌលសុខភាពស្ទឹងមានជ័យ |
| ១២ | ខណ្ឌសែនសុខ | មណ្ឌលសុខភាពឃ្មួញ |
| | | មន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជា-ចិន សែនសុខ |
| ១៣ | ខណ្ឌដង្កោ | មណ្ឌលសុខភាពព្រៃវែង |
| | | មន្ទីរពេទ្យបង្អែកដង្កោ |
| ១៤ | ខណ្ឌព្រែកព្នៅ | មណ្ឌលសុខភាពពញាពន់ |
| | | មន្ទីរពេទ្យបង្អែកព្រែកព្នៅ |

សូមអញ្ជើញទំនាក់ទំនងជាមួយអាជ្ញាធរសង្កាត់ដែលលោកអ៊ំ ពូ មីង ពុក ម៉ែ បងប្អូនទាំងអស់រស់នៅបច្ចុប្បន្ន ដើម្បីចុះឈ្មោះ និងសម្របសម្រួលចាក់វ៉ាក់សាំងដោយស្ម័គ្រចិត្តឱ្យបានឆាប់ជាទីបំផុត អនុវត្តន៍តាមការណែនាំ និងការអញ្ជើញពីអាជ្ញាធរសង្កាត់ ទៅតាមកម្មវិធីចាក់វ៉ាក់សាំងតាមពេលវេលាកំណត់ដើម្បីចៀសវាងការមកកកកុញ ចាំយូរនៅកន្លែងចាក់វ៉ាក់សាំង ដែលបង្កជាហានិភ័យនៃការចម្លងវីរុសកូវីដ-១៩ ដែលកំពុងតែចរាចរយ៉ាងសកម្មនៅរាជធានីភ្នំពេញ និងដើម្បីការពារខ្លួនយើង គ្រួសារយើង និងសហគមន៍យើង។ សូមជម្រាបជូនផងដែរថា ការចាក់វ៉ាក់សាំងនេះ ត្រូវធ្វើទៅតាមខណ្ឌនីមួយៗ ដែលមានទីតាំងផ្តល់សេវាចាក់វ៉ាក់សាំងដូចមានបង្ហាញជូនក្នុងតារាងខាងលើនេះស្រាប់ និងសូមលោកពូ អ៊ុំ មា មីង ទាំងអស់ដែលស្ម័គ្រចិត្តអញ្ជើញមកចាក់វ៉ាក់សាំង ត្រូវអញ្ជើញមកតាមការសម្របសម្រួលរបស់អាជ្ញាធរសង្កាត់ជាចាំបាច់ ដោយមិនអនុញ្ញាតឱ្យមានការចាក់ជូនសម្រាប់បុគ្គលដែលអញ្ជើញមកដោយខ្លួនឯង ដែលគ្មានការសម្របសម្រួលពីអាជ្ញាធរមូលដ្ឋាននោះឡើយ។

ជាមួយគ្នានោះដែរ ទោះបីជាបុគ្គលម្នាក់ៗបានទទួលវ៉ាក់សាំងហើយក្តី ក៏ត្រូវតែបន្តចូលរួមអនុវត្តវិធានសុខាភិបាលត្រួតពិនិត្យ និងការពារហានិភ័យនៃការចម្លងជំងឺកូវីដ-១៩ និងកាត់បន្ថយផលប៉ះពាល់លើសេដ្ឋកិច្ច និងសង្គមដោយបន្តអនុវត្តនូវវិធានការ ៣ការពារ (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពីមួយម៉ែត្រកន្លះឡើង) និង៣កុំ (កុំទៅកន្លែងមានមនុស្សកុះករច្រើន កុំទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា) ដែលបានដាក់ចេញឱ្យអនុវត្តន៍ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ចៀសវាងបាននូវការឈឺ និងស្លាប់ដោយសារជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ ក៏ដូចជានៅក្នុងប្រទេសកម្ពុជា ។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានបញ្ហាសុខភាព ឬមានជំងឺ ឬសង្ស័យថាមាការឆ្លងជំងឺ សូមប្រញាប់ទៅស្វែងរកការពិនិត្យពិគ្រោះនៅមន្ទីរពេទ្យរដ្ឋ ឬទំនាក់ទំនងតាមលេខទូរស័ព្ទទាន់ហេតុការណ៍របស់ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨។

គណកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស នឹងបន្តធ្វើការជូនដំណឹងដល់សាធារណជនអំពីផែនការចាក់វ៉ាក់សាំងកូវីដ-១៩ ជាបន្តបន្ទាប់ទៀត នៅពេលដែលមានវ៉ាក់សាំងមកដល់បន្ថែមទៀតនាពេលខាងមុខ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលេខទូរស័ព្ទ ០៧៧ ៨២៤ ៨២៤ ឬ ០១២ ៩៦០ ៧២៧ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃច័ន្ទ ៩ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ពស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១
**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស**

**វេជ្ជ. ឱ្យ វណ្ណឌីន**